ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៣៦/២២.....អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តប៉ៃលិន"

ព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តប៉ៃលិន»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ជា ចាន់ឋិន ប្រធានក្រុមប្រឹក្សាខេត្ត**
- **លោក អោម សារិន ចៅសង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបំផុស និងបង្ហាញជាសាធារណៈ នូវយន្តការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាប្រវត្តិសាស្ត្ររបស់កម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងកិច្ចរក្សាបាននូវការជឿទុកចិត្ត ចូលរួម និងគាំទ្រពីប្រជាពលរដ្ឋ តាមយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

## I. សេចក្តីផ្តើម

ខេត្តប៉ៃលិន មានផ្ទៃដីសរុប ១០៦២ គីឡូម៉ែត្រការ៉េ មានក្រុង ០១ និងស្រុក ០១ បែងចែកជា ០៨ ឃុំ សង្កាត់ ស្មើនឹង ៩០ភូមិ មានប្រជាពលរដ្ឋសរុបចំនួន ១៦ ៥៨៨ គ្រួសារ ស្មើនឹង ៧១ ៤៨៣ នាក់ ស្រី ៣៤ ១៥៣ នាក់។ សក្តានុពលសេដ្ឋកិច្ចរបស់ខេត្ត គឺពឹងផ្អែកលើវិស័យកសិកម្មជាចម្បង ដោយប្រជាពលរដ្ឋប្រមាណ ៧០% ប្រកបមុខរបរកសិកម្ម ចំពោះវិស័យផ្សេងៗទៀតដូចជា វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម និងការវិនិយោគនានា នៅមិនទាន់មានការរីកខ្លាំងនៅឡើយ។

## II. វឌ្ឍនភាពការងារសំខាន់ៗ

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តប៉ៃលិន អាណត្តិទី៣ មានសមាជិកសរុបចំនួន ១៥នាក់ ស្រី ៣នាក់ ក្រុមប្រឹក្សា ក្រុង ស្រុក មាន ចំនួន ៣០នាក់ ស្រី ០៧នាក់ និងក្រុមប្រឹក្សា ឃុំ សង្កាត់ មានចំនួន ៥២នាក់ ស្រី ១៥ នាក់។ ដោយផ្អែកលើតួនាទី និងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូន ក្រុមប្រឹក្សាខេត្ត សម្រេចបាននូវ វឌ្ឍនភាពសំខាន់ៗ ដូចជា៖

- បានរៀបចំកិច្ចប្រជុំសាមញ្ញចំនួន ៣២លើក ដោយបានដាក់ចេញនូវដីកា សេចក្តីសម្រេច និង លិខិតបទដ្ឋានគតិយុត្ត ចំនួន ០៨ និងអនុម័តលើឯកសារ ដីកា បទបញ្ជាផ្ទៃក្នុង សេចក្តី សម្រេចផ្សេងៗ ដែលជាផែនការអភិវឌ្ឍខេត្ត
- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត ពិធីប្រកាស ពិធីសម្ពោធសមិទ្ធផលនានា ពិធី សំណេះសំណាល វគ្គបណ្តុះបណ្តាល និងពិធីផ្សេងៗ ក្នុងខេត្តចំនួន ១០៧ លើក និងក្រៅខេត្ត ចំនួន ១៦ លើក
- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត សម្រាប់ ឆ្នាំ២០១៩ នៅលើក្រុង ស្រុក ទាំង ០២ ក្នុងខេត្ត ដែលមានអ្នកចូលរួមសរុប ចំនួន ៣៥៨ នាក់ ស្រី ៧០ នាក់ ដោយទទួលបានសំណើ សំណូមពរ ចំនួន ២២ ករណី ក្នុងនោះបានធ្វើការបកស្រាយ និងដោះស្រាយរួចចំនួន២២ ករណី
- បានចុះអប់រំ ផ្សព្វផ្សាយអំពីវិធានការការពារ និងបង្ការការឆ្លងជំងឺកូវីដ-១៩ នៅតាមមូលដ្ឋាន និងចុះត្រួតពិនិត្យមើលការរៀបចំទីតាំងពិនិត្យសុខភាពនៅតាមព្រំដែននៃប្រទេសថៃ និងតាម មណ្ឌលធ្វើចត្តាឡីស័ក ព្រមទាំងបានចែកអំណោយ និងសម្ភារៈការពារជំងឺកូវីដ-១៩ ដល់ ពលករដែលទើបត្រឡប់មកពីក្រៅប្រទេស
- បានផ្តល់ជាអនុសាសន៍មួយចំនួនជូនដល់គណៈអភិបាលខេត្ត ដើម្បីយកទៅរៀបចំចាត់ចែង និងកែលម្អ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅតាមទីប្រជុំជន ក្រុង ស្រុក ការការពារ ថែ រក្សា ទ្រព្យសម្បត្តិ និងសមិទ្ធផលសាធារណៈ បញ្ហាទំនាស់ផ្សេងៗ នៅមូលដ្ឋាន បញ្ហាអគ្គិសនី និងទឹកស្អាត បញ្ហាហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ប្រឡាយទឹក បញ្ហាគ្រោះមហន្តរាយ និងការដោះ ស្រាយនូវកង្វល់ សំណើ សំណូមពរ របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

❖ **សង្កាត់អូរតាវៅ ក្រុងប៉ៃលិន**

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាសង្កាត់សម្រេចបានរួមមាន៖

- បានកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុងអាមេ ២ខ្សែ ផ្លូវបេតុង ១ខ្សែ ផ្លូវក្រាលគ្រួស ៣ខ្សែ ស្ពានប្រព័ន្ធលូរំដោះទឹកក្នុងសង្កាត់ ព្រមទាំងប្រព័ន្ធបណ្ដាញអគ្គិសនីប្រលប្រាស់គ្រប់ភូមិទាំងអស់នៅក្នុងសង្កាត់។
- មានរមណីយដ្ឋានទឹកធ្លាក់ចំនួន១ ដែលជួយទ្រទ្រង់សេដ្ឋកិច្ច និងផ្ដល់ការងារជូនប្រជាពលរដ្ឋក្នុងសង្កាត់
- បានគាំទ្រដល់វិស័យគាំពារសង្គម ដោយបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ជនងាយរងគ្រោះ ក្មេងកំព្រា ស្ត្រីមានផ្ទៃពោះ ព្រមទាំងបានផ្តល់បង្គន់អនាម័យដល់គ្រួសារក្រីក្រសរុប ៣០ គ្រួសារ
- បានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងបានដោះស្រាយ និងសម្របសម្រួលទំនាស់សរុប ១៥ករណី។

## III. ទិសដៅការងារបន្ត

❖ **ក្រុមប្រឹក្សាខេត្ត**

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- ចូលរួមផ្តល់យោបល់ និងកំណត់ទិសដៅជូនរដ្ឋបាលខេត្ត ក្នុងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត ជូនប្រជាជនប្រើប្រាស់ និងបម្រើការធ្វើអាជីវកម្ម និងការវិនិយោគផ្សេងៗ
- បន្តតាមដាន ត្រួតពិនិត្យមើលការកែលម្អ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា សម្រាប់ចូលរួម ចលនាប្រឡងប្រណាំងទីក្រុងស្អាត និងការទាក់ទាញភ្ញៀវទេសចរ ទាំងក្នុងស្រុក និងបរទេសឱ្យចូលមកកំសាន្តនៅក្នុងខេត្ត
- បន្តតាមដាន និងជម្រុញការចុះបញ្ជីដីធ្លីទាំងលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ ដើម្បីធានាបាននូវការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធភាព និងចូលរួមកាត់បន្ថយ បញ្ហាទំនាស់ដីធ្លី
- បន្តដោះស្រាយទំនាស់ សំណូមពរ និងកង្វល់ទាំងឡាយរបស់ប្រជាពលរដ្ឋ ដែលបានមកតាមរយៈការធ្វើវេទិការបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់។

❖ **សង្កាត់អូរតាវៅ ក្រុងប៉ៃលិន**

- បន្តខិតខំពង្រឹងកំលាំងនគរបាលប៉ុស្តិ៍ និងប្រជាការពារ ដើម្បីអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

- បន្តផ្សព្វផ្សាយ និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ យល់ដឹងអំពីច្បាប់ និងលិខិតបទដ្ឋាននានា គោលការណែនាំ បញ្ជ្រាបចំណេះដឹង ក្នុងការបង្កើតមុខរបរខ្នាតតូច ជូនដល់ប្រជាពលរដ្ឋ
- បន្តផ្សព្វផ្សាយពីវិធានការការពារ ទប់ស្កាត់ជំងឺឆ្លងនានា ជាពិសេសជំងឺកូវីដ១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល និងរបៀបរស់នៅស្អាត ហូបស្អាត និងការធ្វើ អនាម័យបរិស្ថាន
- ផ្សព្វផ្សាយ និង ណែនាំដល់ប្រជាពលរដ្ឋអោយចេះវេចខ្ចប់ទុកដាក់ សម្រាម និង កាកសំណល់ឱ្យបានត្រឹមត្រូវ
- ខិតខំគៀងគរដៃគូ អ្នកវិនិយោគសប្បុរសជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងសង្កាត់។

## IV. សម្គាល់

រដ្ឋបាលខេត្តប៉ៃលិន បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ អនុវត្តបានចំនួន ១០ ៤៤៩នាក់ សរុបទឹកប្រាក់ ៦០១ ៣៥០ ០០០រៀល និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ បានចំនួន ៥ ៥៥៥ គ្រួសារ សរុបជាទឹកប្រាក់ ១៥ ៣៨២ ៩៦៥ ០០០រៀល និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជំនួយសង្គម ក្នុងអំឡុងពេលបិទខ្ទប់ចំនួន ៣៥ គ្រួសារ សរុបទឹកប្រាក់ ១០ ៣៥០ ៩០០រៀល។ ក្នុងការអនុវត្តនូវវិធានការនានារបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធភាព នៃការងារប្រយុទ្ធប្រឆាំងការរីករាលដាលនៃជំងឺកូវីដ-១៩ រដ្ឋបាលខេត្ត បានជួយឧបត្ថម្ភជីវភាពដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងពលករដែលវិលត្រឡប់មកពីប្រទេសថៃ និងបានរៀបចំឱ្យមានជាមណ្ឌលចត្តាឡីស័ក មណ្ឌលព្យាបាលជំងឺ និងបានផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សរុប ១៧៩ ២៤៣ ដូស ជូនដល់ប្រជាពលរដ្ឋអាយុចាប់ពី ៥ឆ្នាំឡើង កម្មករ កម្មការនី បុគ្គលិកក្រុមហ៊ុន រោងចក្រ អតីតយុទ្ធជន ប្រជាពលរដ្ឋខ្មែររស់នៅតាមផ្សារព្រំដែនថៃ រួមទាំងបុគ្គលិក មន្ត្រីរាជការ ទាំងដូសទី១ ទី២ ទី៣ និងទី៤ សរុបចំនួន ៧៦,៦៣៦នាក់។ ដោយឡែក នៅទូទាំងខេត្តប៉ៃលិន មានអ្នកមកធ្វើចត្តាឡីស័ក សរុបចំនួន ១៩ ០២៨ នាក់, អ្នកឆ្លងជំងឺកូវីដ-១៩ សរុបចំនួន ២ ៨៩៦នាក់, ជាសះស្បើយ សរុបចំនួន ២ ៨១៦ នាក់ និងមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ សរុបចំនួន ០៨ នាក់។៚

ថ្ងៃអង្គារ ១រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២